Australian Government

Job Services Australia™
people • skills • jobs

# Work Experience: Green Corps

**អង្គភាពបៃតង (Green Corps) អាចជួយលោកអ្នកឱ្យអនុវត្តសកម្មភាពដែលផ្តល់ផលប្រយោជន៍ ដល់បរិស្ថានធម្មជាតិ និងមរតកវប្បធម៌អូស្ត្រាលី ។ Green Corps ជួយអភិរក្ស ការពារ និងស្តារបរិស្ថានអូស្ត្រាលី ទន្ទឹមនឹងការផ្តល់ឱកាសពង្រីកជំនាញដល់លោកអ្នកផងដែរ។**

សកម្មភាព Green Corps រៀបចំឡើងដោយអង្គការមិនស្វែងរកប្រាក់ចំណេញ ឬស្ថាប័ន និងទីភ្នាក់ងាររដ្ឋាភិបាលអូស្ត្រាលីនៅតាមតំបន់ តាមរដ្ឋ ឬដែនដី។

Green Corps បានពង្រីកសកម្មភាពរបស់ខ្លួន តាមរយៈស្ថាប័នផ្តល់សេវាការងារអូស្ត្រាលី (Job Services Australia) ហើយបច្ចុប្បន្នមានសកម្មភាពសម្រាប់អ្នកស្វែងរកការងារធ្វើគ្រប់វ័យ។

ការចូលរួមសកម្មភាពរបស់ Green Corps អាចធ្វើឡើងជាក្រុម ដោយធ្វើការក្នុងលក្ខណៈជាក្រុមជាមួយនឹងអ្នកស្វែងរកការងារធ្វើផ្សេងៗទៀត ឬធ្វើការងារដោយឡែករៀងៗខ្លួន ជាមួយអង្គការរៀបចំ (ដូចជា ក្រុមសហគមន៍ ឬក្រុមសប្បុរសធម៌) ។

សកម្មភាព Green Corps មានលក្ខណៈខុសៗគ្នា ប៉ុន្តែក្នុងនាមជាអ្នកស្វែងរកការងារធ្វើ លោកអ្នកប្រហែលជាត្រូវចូលរួមក្នុងកិច្ចការច្រើនប្រភេទ ដូចជា ៖

- ការស្ទង់អង្កេត និងប្រមូលទិន្នន័យអំពីដី ទឹក និងសត្វព្រៃ ដើម្បីរួមចំណែកក្នុងការស្រាវជ្រាវ និងពិនិត្យតាមដានបរិស្ថាន។
- ការថែសួនឧទ្យាន និងការរៀបចំប្លង់ទេសភាព ការសិក្សាអំពីរុក្ខជាតិ និងការចូលរួមក្នុងសកម្មភាពដាំដើមឈើឡើងវិញ។
- ការសិក្សាអំពីការគ្រប់គ្រងធនធានធម្មជាតិ និងការប្រើប្រាស់ធនធានទាំងនោះប្រកបដោយនិរន្តរភាព។
- ការរួមចំណែកក្នុងយុទ្ធសាស្ត្របរិស្ថានតាមតំបន់ ការស្តារមរតកវប្បធម៌ និងការធ្វើផែនការសម្រាប់សកម្មភាព Green Corps។
- ការត្រួតពិនិត្យលើការចេញចូលតំបន់ធម្មជាតិ ការដាំព្រៃគម្លោចឡើងវិញ ការការពារ និងស្តារជម្រកសត្វ ការគ្រប់គ្រងរុក្ខជាតិបរិស្ថាន ព្រមទាំងការសាងសង់ និងស្តារផ្លូវដើរក្នុងព្រៃ។
- ការចូលរួមចំណែកក្នុងការអប់រំសហគមន៍ និងការលើកកម្ពស់ការយល់ដឹង។
- ការឆ្លើយតបនឹងផលប៉ះពាល់ បណ្តាលមកពីការប្រែប្រួលធាតុអាកាស។

សកម្មភាព Green Corps ក៏អាចធ្វើឡើង ដោយសហការជាមួយនឹងកម្មវិធីក្រោមគម្រោងផ្តួចផ្តើមរបស់រដ្ឋាភិបាលអូស្ត្រាលី មានឈ្មោះថា *ការថែទាំប្រទេសយើង (Caring For our Country)*។

សកម្មភាពដែលផ្តល់ឲ្យដោយស្ថាប័ន Job Services Australia នីមួយៗ មានច្រើនប្រភេទ ហើយអាចមានទាំងជម្រើសច្រើនជាងសកម្មភាពដែលបានរៀបរាប់ខាងលើ។

ស្ថាប័នផ្តល់ Job Services Australia ត្រូវធានាឲ្យច្បាស់ថា សកម្មភាព Green Corps ៖

- ចំណាយពេលលើកិច្ចការបរិស្ថានយ៉ាងតិច ៨0ភាគរយ នៃរយៈពេលសកម្មភាពសរុប។
- ផ្តល់នូវការបណ្តុះបណ្តាលហ្វឹកហ្វឺនដែលបានរៀបចំ សម្រាប់អ្នកស្វែងរកការងារធ្វើដែលត្រូវចូលរួម តាមកាលៈទេសៈសមស្រប និងប្រសិនបើអាចធ្វើបាន។
- ផ្តល់ការបណ្តុះបណ្តាលហ្វឹកហ្វឺនពាក់ព័ន្ធនឹងការសង្គ្រោះបឋម ឬសុខភាព និងសុវត្ថិភាពការងារ។

## តើអ្នកណាអាចចូលរួមបាន?

ប្រសិនបើលោកអ្នកជាអ្នកស្វែងរកការងារធ្វើដែលបានចុះឈ្មោះជាមួយស្ថាប័ន Job Services Australia លោកអ្នកអាចស្ម័គ្រចិត្តចូលរួមជាមួយ Green Corps ពេលណាក៏បាន ក្នុងករណីដែលលោកអ្នក និងស្ថាប័នផ្តល់សេវា Job Services Australia របស់លោកអ្នកយល់ឃើញថាការស្ម័គ្រចិត្តនេះនឹងផ្តល់ប្រយោជន៍ដល់លោកអ្នក។

លើសពីនេះ ប្រសិនបើលោកអ្នកជាអ្នកស្វែងរកការងារធ្វើដែលមានតម្រូវការសកម្មភាពបទពិសោធន៍ការងារ (Work Experience Activity Requirement) លោកអ្នកអាចបំពេញតាមតម្រូវការនេះ តាមរយៈការចូលរួមជាមួយ Green Corps។

ប្រសិនបើលោកអ្នកជាអ្នកស្វែងរកការងារធ្វើដែលត្រូវបំពេញសកម្មភាពសកម្មខ្លាំងក្លា (Intensive Activity) លោកអ្នកអាចបំពេញតាមតម្រូវការនេះ ដោយការចូលរួមជាមួយ Green Corps។ ស្ថាប័នផ្តល់ Job Services Australia របស់លោកអ្នកនឹងផ្តល់ការណែនាំដល់លោកអ្នក ថាតើលោកអ្នកត្រូវបំពេញ Intensive Activity ឬយ៉ាងណា។

ប្រសិនបើលោកអ្នកជាអ្នកស្វែងរកការងារធ្វើដែលទទួលជំនួយទ្រទ្រង់ប្រាក់ចំណូល ហើយចូលរួមក្នុង Green Corps លោកអ្នកនឹងមានសិទ្ធិទទួលបានប្រាក់បន្ថែមចំនួន $20.80 ក្នុងពេល២សប្តាហ៍ម្តង ដើម្បីជួយសម្រាលដល់បន្ទុកនៃថ្លៃចូលរួម។

## របៀបដាក់ពាក្យសុំធ្វើការ

ប្រសិនបើលោកអ្នកជាអ្នកស្វែងរកការងារធ្វើដែលមានចំណាប់អារម្មណ៍ចំពោះការចូលរួមក្នុង Green Corps លោកអ្នកគួរពិភាក្សាជាមួយស្ថាប័នផ្តល់ Job Services Australia របស់លោកអ្នក។

9FS09446JSA/khmer

# ភារពកិច្ចរបស់លោកអ្នក

ប្រសិនបើលោកអ្នកទទួល Newstart , ប្រាក់ឧបត្ថម្ភយុវជន (Youth Allowance) ឬប្រាក់ជំនួយសម្រាប់ចិញ្ចឹមកូន (Parenting Payment) ដោយមានការតម្រូវឲ្យចូលរួម លោកអ្នកនឹងត្រូវស្វែងរកការងារ ហើយចូលរួមក្នុងសកម្មភាព ដែលនឹងជួយឱ្យលោកអ្នកបានទទួលការងារធ្វើ។

ស្ថាប័នផ្តល់ Job Services Australia នឹងពិចារណាអំពីស្ថានភាពរបស់លោកអ្នកផ្ទាល់ ហើយចរចាអំពីសកម្មភាពសមរម្យ ដើម្បីដាក់បញ្ចូលក្នុងផែនការរកការងារធ្វើ (Employment Pathway Plan) របស់លោកអ្នក។

ប្រសិនបើលោកអ្នកមិនអាចចូលរួមក្នុងសកម្មភាពទាំងនេះបានទេ លោកអ្នកគួរពិភាក្សាជាមួយស្ថាប័នផ្តល់សេវារបស់លោកអ្នក។ ប្រសិនបើលោកអ្នកខកខានមិនបានអនុវត្តសកម្មភាពដែលបានព្រមព្រៀងនោះ ការខកខាននេះអាចប៉ះពាល់ដល់ប្រាក់ជំនួយទ្រទ្រង់ប្រាក់ចំណូលរបស់លោកអ្នក។

# សិទ្ធិឯកជនរបស់លោកអ្នក

ព័ត៌មានផ្ទាល់ខ្លួនរបស់លោកអ្នក ត្រូវបានការពារដោយ*ច្បាប់ឯកជនឆ្នាំ១៩៨៨ (Privacy Act 1988)* ហើយព័ត៌មានអំពីលោកអ្នក អាចត្រូវបានការពារផងដែរដោយ*ច្បាប់ (រដ្ឋបាល) សន្តិសុខសង្គមឆ្នាំ១៩៩៩ (Social Security [Administration] Act 1999)* (ឧទាហរណ៍ ប្រសិនបើលោកអ្នកទទួលប្រាក់ជំនួយទ្រទ្រង់ប្រាក់ចំណូល)។ ព័ត៌មានរបស់លោកអ្នកអាចត្រូវស្ថាប័នផ្តល់ Job Services Australia ព្រមទាំងក្រសួងអប់រំការងារ និងទំនាក់ទំនងកន្លែងធ្វើការ [DEEWR], (Department of Education, Employment and Workplace Relations [DEEWR]) ប្រើប្រាស់រួមគ្នាជាមួយ Centrelink និងក្រសួង ក៏ដូចជាទីភ្នាក់ងាររដ្ឋាភិបាលអូស្ត្រាលីផ្សេងៗទៀត ដើម្បីផ្តល់លទ្ធភាពឱ្យអង្គការទាំងនោះ ផ្តល់ជូនលោកអ្នកនូវសេវាដ៏សមស្របបំផុត ដើម្បីបំពេញតាមតម្រូវការរបស់លោកអ្នក។

ចំពោះព័ត៌មានបន្ថែមអំពីភាពឯកជនរបស់លោកអ្នក សូមសាកសួរស្ថាប័នផ្តល់ Job Services Australia របស់លោកអ្នក DEEWR ឬបើកមើលវ៉ិបសាយថ៍ **privacy.gov.au** ។

# ការធានាផ្តល់ សេវារបស់យើងជូនលោកអ្នក

## ការធានាសេវា

លោកអ្នកនឹងទទួលបានសេវាការងាររៀបចំឡើងសម្រាប់រូបលោកអ្នកផ្ទាល់ដែលផ្តល់ដោយស្ថាប័នផ្តល់ Job Services Australia ។ សេវាទាំងនេះនឹងមានលក្ខណ:បត់បែនទៅតាមស្ថានភាព និងប្រវត្តិការងាររបស់លោកអ្នក។ ដើម្បីមើលពីការធានារបស់សេវាទាំងអស់នេះ សូមចូលទៅវ៉ិបសាយថ៍ **deewr.gov.au/jobservicesaustralia** ។

## ក្រមសីលធម៌វិជ្ជាជីវ:

ស្ថាប័នផ្តល់ Job Services Australia ចុះកិច្ចសន្យាដើម្បីផ្តល់សេវាការងារដែលឧបត្ថម្ភថវិកាដោយរដ្ឋាភិបាលអូស្ត្រាលី និងបានយល់ព្រម ហើយប្តេជ្ញាប្រតិបត្តិតាមក្រមសីលធម៌វិជ្ជាជីវ: ក្នុងការផ្តល់សេវាការងារនេះ។ ដើម្បីមើលក្រមសីលធម៌វិជ្ជាជីវ: សូមចូលទៅវ៉ិបសាយថ៍ **deewr.gov.au/jobservicesaustralia**។

# សម្រាប់ព័ត៌មានបន្ថែម

**សូមទូរស័ព្ទទៅលេខ 13 17 64 ឬបើកមើលវ៉ិបសាយថ៍ deewr.gov.au/jobservicesaustralia ។**